**Job Access**

**Driving disability employment**

# បណ្ណព័ត៌មាន

# តើអ្នកជាជនវ័យក្មេងដែលមានពិការភាពហើយកំពុងស្វែងរកការងារធ្វើឬ?

មានសេវាផ្សេងៗដោយឥតគិតថ្លៃដែលអាចជួយអ្នកនៅខណៈដែលអ្នកកំពុងបញ្ចប់ការសិក្សា វគ្គបណ្តុះ បណ្តាល ឬការសិក្សាថ្នាក់កំរិតឧត្តម និងឈានទៅធ្វើការ ។ សេវាទាំងនេះមានរួមទាំង ៖

## សេវាការងារសម្រាប់ជនពិការ (Disability Employment Services) (DES)

សេវាការងារសម្រាប់ជនពិការ ជួយដល់បណ្តាប្រជាជនវ័យក្មេងដែលមានសិទ្ធិទទួល  ដោយសារមានពិការ ភាព របួស ឬលក្ខណៈសុខភាព ក្នុងការស្វែងរក និងរក្សារការងារ ។

## កម្មវិធីអភិវឌ្ឍសហគមន៍

កម្មវិធីអភិវឌ្ឍសហគមន៍ (Community Development Programme) (CDP) អាចជួយអ្នកប្រសិនជាអ្នករស់នៅតំបន់ដាច់ស្រយាលក្នុងប្រទេសអូស្ត្រាលី នឹងកំពុងស្វែងរកការងារធ្វើ។

## ដំណាក់កាលឈានទៅធ្វើការ (Transition to Work) (TTW)

ប្រសិនជាអ្នកមានអាយុរវាង 15  និង 21 ឆ្នាំ អ្នកអាចទទួលបានជំនួយតាមរយៈ TTW ។ TTW អាចជួយអ្នកត្រៀមខ្លួនសំរាប់ការងារតាមរយៈការបណ្តុះបណ្តាលស្តីពីអាកប្បកិរិយានៅទីកន្លែងការងារ និងការរំពឹងទុកនានានៅទីកន្លែងការងារ  ព្រមទាំងការអភិវឌ្ឍជំនាញផ្សេងៗសំរាប់ការងារ និងការសិក្សា ។

## មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និងការងារ (Vocational, Training & Employment Centres) (VTECs)

បើអ្នកជាអ្នកស្វែងរកការងារវ័យក្មេង និងជាមនុស្សជនជាតិដើមនៃប្រទេសអូស្ត្រាលី (Indigenous) មានពិការភាព និងកំពុងស្វែងរកការងារធ្វើ នោះ VTECs អាចជួយអ្នកបាន ។

## កម្មវិធីហ្វឹកហ្វឺនជំនាញការងារ  និងកម្មវិធីបង្ហាត់បង្រៀនធ្វើការ

អ្នកអាចចាប់អារម្មណ៍និងកម្មវិធីហ្វឹកហ្វឺនជំនាញការងារ ឬក៏កម្មវិធីបង្ហាត់បង្រៀនធ្វើការ ដែលជាវិធីមួយក្នុងការទទួលបានសញ្ញាបត្រ័ការងារ និងការងារធ្វើតែម្តង ។

បើលោកអ្នកចង់បានព័ត៌មានបន្ថែមស្តីអំពីសេវាទាំងនេះ លោកអ្នកអាចមើលទំព័រ JobAccess  នៅ www.jobaccess.gov.au ឬក៏ទាក់ទងមកអ្នកផ្តល់យោបល់របស់ JobAccess តាមរយៈលេខ 1800 464 800 – ការទាក់ទងតាមទូរសព្ទ័ដៃត្រូវគេគិតថ្លៃ។

---

Australian Government

JobAccess is the national hub for workplace and employment information for people with disability, employers and service providers.

**1800 464 800** **www.jobaccess.gov.au**